**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ០៨ ប្រ.ក.ព

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

## ថ្ងៃសុក្រ ៧រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

## ត្រូវនឹងថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០

នៅព្រឹកថ្ងៃសុក្រ ៧រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

**១-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២១-២០២៣។**

**២-សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣។**

**៣-បញ្ហាផ្សេងៗ៖**

សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ៖

៣.១- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារខណ្ឌសីមានិងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម។

៣.២- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

១-ពិធីសារទី៣ ស្តីពីសិទ្ធិសហការលើជើងហោះហើរក្នុងស្រុក ក្នុងរង្វង់ទឹកដីនៃប្រទេសជាសមាជិកអាស៊ានណាមួយ។

២-ពិធីសារទី៤ ស្តីពីសិទ្ធិហោះហើរភូធ័រមីណាល (Co-Terminal Rights) រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន។

៣.៣-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩ និងទី១០នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម។

៣.៤- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ។

ក្រោយពីបានស្តាប់របាយការណ៍និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេច៖

## ១-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២១-២០២៣

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.)៣ឆ្នាំរំកិល ២០២១-២០២៣ មានគោលបំណង បង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួងស្ថាប័ន ដែលជាគោលនយោបាយមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣។

សេចក្តីព្រាង ក.វ.ស. ៣ឆ្នាំរំកិល ២០២១-២០២៣ បានដាក់បញ្ចូលគ្មានូវគម្រោងកំពុងដំណើរការ ដែលការអនុវត្តគម្រោងកំពុងបន្តនៅក្នុងដំណាក់កាល ក.វ.ស. និងគម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ. ដែលជាគម្រោងស្នើសុំថ្មីត្រូវអនុវត្តក្នុងដំណាក់កាល ក.វ.ស.។ ចំពោះ ក.វ.ស. ៣ឆ្នាំរំកិល ២០២១-២០២៣នេះ មានគម្រោងសរុបចំនួន៦២៩ ដែលត្រូវការបរិមាណទុនសរុប ១២ ៧៩៦លានដុល្លារអាម៉េរិក ដោយក្នុងនោះ ២០៣ជាគម្រោងកំពុងដំណើរការ ដែលត្រូវការទុនចំនួន ៨ ៣៩៧លានដុល្លារអាម៉េរិក និង ៤២៦ជាគម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ. ឬគម្រោងថ្មី ដែលត្រូវការទុនចំនួន ៤ ៣៩៩លានដុល្លារអាម៉េរិក។

ការវិភាជទុនដល់គម្រោងនានារបស់ ក.វ.ស. ៣ឆ្នាំរំកិល ២០២១-២០២៣ ទៅតាមវិស័យនីមួយៗ ត្រូវបានកំណត់៖ ៨,៩%សម្រាប់គម្រោងក្នុងវិស័យសង្គមកិច្ច ៣៤,២%សម្រាប់គម្រោងក្នុងវិស័យសេដ្ឋកិច្ច ៥០,១%សម្រាប់គម្រោងក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និង ៦,៨%សម្រាប់គម្រោងក្នុងវិស័យសេវានិងកម្មវិធីអន្តរវិស័យ។

សេចក្តីព្រាង ក.វ.ស. ៣ឆ្នាំរំកិល ២០២១-២០២៣ ត្រូវបានរៀបចំឡើងមាន៨ជំពូកនិងបញ្ជីតារាងចំនួន១១ ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

## ២-សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣

កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ចំនួនពីរ(ទី១ ឆ្នាំ២០០៩-២០១៣ និងទី២ ឆ្នាំ២០១៤-២០១៨)។ ប៉ុន្តែក៏នៅមានបញ្ហាសេសសល់ និងបញ្ហាប្រឈមថ្មីៗដែលបណ្តាលមកពីការរីកចម្រើនយ៉ាងឆាប់រហ័សរបស់សង្គម ប្រព័ន្ធព័ត៌មានវិទ្យា និងសាកលភាវូបនីយកម្ម។ ស្ត្រីកម្ពុជាមួយចំនួននៅតែប្រឈមមុខនឹងអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចទាំងនៅក្នុងផ្ទះ នៅកន្លែងធ្វើការ និងក្នុងសហគមន៍ ដោយមិនគិតពីកម្រិតប្រាក់ចំណូល កម្រិតវប្បធម៌ និងចំណេះដឹងឡើយ ខណៈដែលមូលហេតុចម្បងត្រូវបានទទួលស្គាល់ជាទូទៅថាបណ្តាលមកពីវិសមភាពយេនឌ័រនិងការរើសអើង។

ក្នុងន័យនេះ សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពីហិង្សាលើស្ត្រី ២០១៩-២០២៣ គឺជាផែនការលើកទី៣ ដែលត្រូវបានរៀបចំឡើងដើម្បីជាផែនទីតម្រង់ទិសសម្រាប់បណ្តាក្រសួងស្ថាប័នអ្នកពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយ ក្នុងការបន្តអនុវត្តការងារបង្ការ ទប់ស្កាត់ ឆ្លើយតប និងដោះស្រាយអំពើហិង្សាលើស្ត្រីឱ្យកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិខ្ពស់ ក្នុងគោលបំណងឆ្ពោះទៅកាត់បន្ថយរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី ដែលនឹងរួមចំណែកលើកកម្ពស់តម្លៃសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ សំដៅលើកកម្ពស់សមធម៌ បរិយាបន្ន និងភាពសុខដុមរមនាសង្គម ដែលនឹងផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់ស្ត្រីអាចប្រើប្រាស់សក្តានុពលរបស់ខ្លួនជាអតិបរមាដើម្បីចូលរួមក្នុងដំណើរការអភិវឌ្ឍប្រទេសជាតិ។

សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពីហិង្សាលើស្ត្រី ២០១៩-២០២៣ ត្រូវបានរៀបចំឡើងដោយមាន៧ជំពូក ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

៣-បញ្ហាផ្សេងៗ

កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចបញ្ជូនទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ៖

៣.១-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារខណ្ឌសីមានិងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម។

៣.២-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

១- ពិធីសារទី៣ ស្តីពីសិទ្ធិសហការលើជើងហោះហើរក្នុងស្រុក ក្នុងរង្វង់ទឹកដីនៃប្រទេសជាសមាជិកអាស៊ានណាមួយ។

២- ពិធីសារទី៤ ស្តីពីសិទ្ធិហោះហើរគូផ់រមើណល (Co-Terminal Rights) រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន។

៣.៣-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩និងទី១០នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម។

៣.៤-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖

១- ក្នុងបរិបទនៃវិបត្តិជំងឺកូវីដ-១៩ ប្រទេសកម្ពុជានៅរក្សាបាននូវការគ្រប់គ្រងហិរញ្ញវត្ថុក្នុងស្ថានភាពល្អប្រសើរ បើធៀបនឹងបណ្តាប្រទេសមួយចំនួន។ ជាក់ស្តែង រាជរដ្ឋាភិបាលនៅមានលទ្ធភាពគ្រប់គ្រាន់ដើម្បីបញ្ចេញកញ្ចប់ថវិកាសម្រាប់ចំណាយចរន្តក្នុងការបើកបៀវត្សរ៍រៀងរាល់២សប្តាហ៍ម្តងជូនមន្ត្រីរាជការទូទាំងប្រទេស និងបន្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋក្រីក្រនិងងាយរងគ្រោះដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩ ព្រមទាំងគាំទ្រដល់កម្មវិធីវិនិយោគសាធារណៈ ជាអាទិ៍ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ប្រឡាយទឹក និងគម្រោងខ្នាតតូចនៅតាមសហគមន៍មូលដ្ឋាន។

២- ដើម្បីឆ្លើយតបនឹងបញ្ហាគ្រោះទឹកជំនន់ដែលបាននិងកំពុងកើតមាននាពេលបច្ចុប្បន្ន ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ ដោយចាត់វិធានការចាំបាច់នានា និងដឹកនាំកម្លាំងក្នុងការចេញទៅជួយសង្គ្រោះប្រជាពលរដ្ឋតាមភូមិសាស្ត្រដែលទទួលខុសត្រូវឱ្យបានទាន់ពេលវេលា ដើម្បីទប់ទល់នឹងគ្រោះទឹកជំនន់ ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវការលំបាកនិងផលប៉ះពាល់ដល់ទ្រព្យសម្បត្តិនិងអាយុជីវិតរបស់ប្រជាពលរដ្ឋ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង៩និង៥៣នាទី។

ថ្ងៃសុក្រ ៧រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០